# បុព្វកថា

វិស័យព្រៃឈើនៃប្រទេសកម្ពុជាមានសក្តានុពលដ៏ធំធេងក្នុងការរួមចំណែកកាត់បន្ថយភាពក្រីក្រ អភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម និងការពារបរិស្ថាន។ ប៉ុន្តែដោយសារមូលហេតុជាច្រើន ក្នុងរយៈពេលប៉ុន្មានទសវត្សកន្លងមកនេះ ព្រៃឈើមួយចំនួនត្រូវបានក្លាយជាព្រៃរេចរិល ឬបាត់បង់ ។

រាជរដ្ឋាភិបាលកម្ពុជា ដោយមានការចូលរួមពីផ្នែកឯកជន និងដៃគូរអភិវឌ្ឍន៍នានាបានយកចិត្តទុកដាក់ក្នុងកម្មវិធីដាំដើមឈើសំរាប់បំពេញគោលបំណងធ្វើពាណិជ្ជកម្មផង និង សំរាប់ជាផលប្រយោជន៏ដល់សេដ្ឋកិច្ច-សង្គមនិងបរិស្ថានធម្មជាតិផង។ ក៏ប៉ុន្តែគ្រប់កម្មវិធីដាំដើមឈើទាំងអស់មិនសុទ្ធតែទទួលបានជោគជ័យទាំងស្រុងនោះទេ។ ហេតុការណ៏នេះបង្ហាញឱ្យឃើញនូវការទាមទារឱ្យមានការចូលរួមកែលំអពីសំណាក់អ្នកពាក់ព័ន្ធនានាក្នុងការកំណត់ទីតាំងសំរាប់ដាំដើមឈើ ។

គោលកាណ៏ណែនាំសំរាប់កំណត់ទីតាំង និង ការអនុវត្តការងារដាំដើមឈើ ត្រូវបានរៀបចំឡើងនៅក្នុងឱកាសដ៏សមស្របមួយដែលវិស័យព្រៃឈើបានកំពុងដំណើរការធ្វើផែនការគ្រប់គ្រងព្រៃឈើនៅទូទាំងប្រទេស ក្នុងនោះក៏មានការកំណត់តំបន់ដែលទាមទារឱ្យមានការស្តារព្រៃឈើឡើងវិញ។ គោលកាណ៏ណែនាំនេះក៏អាចអនុវត្តបានសំរាប់ការដាំដុះដើមឈើតាមទីតាំងដែលនៅក្រៅតំបន់ព្រៃឈើផងដែរ។

គោលកាណ៏ណែនាំនេះបានលើកមកបង្ហាញផងដែរនូវបទពិសោធន៏ពីបណ្តាប្រទេសនានា ដែលអាចប្រើប្រាស់សំរាប់ជាមូលដ្ឋានក្នុងការកំណត់ទីតាំងសំរាប់ដាំដើមឈើឱ្យបានសមស្រប និងជាមាគ៌ាក្នុងការធ្វើសេចក្តីសំរេចចិត្តមួយដើម្បីឈានទៅរកជោគជ័យ។ លើសពីនេះសៀវភៅនេះក៏បានបង្ហាញយ៉ាងលំអិតនូវបច្ចេកទេសនៃការដាំដើមឈើដោយផ្តោតជាចំបងលើសារសំខាន់នៃការប្រើប្រាស់គ្រាប់ពូជមានគុណភាពល្អ ដែលធានាដល់ការបន្សាំជាមួយនឹងទីកន្លែង និង ដុះលូតលាស់លឿន។ និយាយជារួមការដាំដើមឈើដោយប្រើប្រាស់គ្រាប់ពូជមានគុណភាពល្អ មានសក្តានុពលកែលំអដ៏ធំធេងក្នុងការជួយដោះស្រាយនូវបញ្ហាសង្គម បរិស្ថាន និង ពាណិជ្ជកម្ម។

ក្នុងនាមរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខ្ញុំសូមសំដែងនូវអំណរគុណដ៏ជ្រាលជ្រៅចំពោះគំរោងគ្រាប់ពូជឈើកម្ពុជា និង ស្ថានទូតដាណឺម៉ាក្សប្រចាំនៅភ្នំពេញដែលបានផ្តួចផ្តើមគំនិតបង្កើតស្នាដៃនេះឡើងចូលរួមវិភាគទានដ៏សំខាន់ដល់ការគ្រប់គ្រងព្រៃឈើប្រកបដោយនិរន្តរភាព។ ខ្ញុំក៏សូមសំដែងអំណរគុណចំពោះរាល់ការចូលរួមប្រកបដោយន័យស្ថាបនាទាំងអស់ ជាពិសេសដល់អ្នកនិពន្ធដែលមានលោក សូ ធា ប្រធានគំរោង កញ្ញា សារា បឺគហ្គេស អ្នកពិគ្រោះយោបល់ និង លោក អារីដ ស្លុត ទីប្រឹក្សាដានីដាប្រចាំគំរោងគ្រាប់ពូជឈើកម្ពុជាដែលបានយកអស់កំលាំងកាយចិត្តដឹកនាំដំណើរការផលិតចេញជាឯកសារដ៏មានតំលៃនេះឡើង។

ក្នុងនាមប្រធានរដ្ឋបាលព្រៃឈើ ខ្ញុំគាំទ្រយ៉ាងខ្លាំងក្លាចំពោះគោលកាណ៏ណែនាំសំរាប់កំណត់ទីតាំង និង ការអនុវត្តការងារដាំដើមឈើ និង ត្រូវបានធានាប្រើប្រាស់ ដាក់បញ្ចូលទៅក្នុងការធ្វើផែនការគ្រប់គ្រងវិស័យព្រៃឈើជាចាំបាច់។

**ទី សុគន្ធ**

**ប្រធានរដ្ឋបាលព្រៃឈើ**